**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ......៦៧៦......អពដ

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែ [illegible] ឆ្នាំ២០១៤

# សេចក្តីជូនដំណឹង
## ស្តីពី
## ការរំលឹកការបង់ពន្ធលើអចលនទ្រព្យ និង ការចុះត្រួតពិនិត្យលើអចលនទ្រព្យដែលមិនទាន់ប្រកាសបង់ពន្ធ

អគ្គនាយកដ្ឋានពន្ធដារ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ម្ចាស់អចលនទ្រព្យដែលស្ថិតនៅរាជធានីភ្នំពេញ និងនៅតាមក្រុងនីមួយៗនៃខេត្តទាំងអស់នៃព្រះរាជាណាចក្រកម្ពុជា មេត្តាជ្រាបថា ពន្ធលើអចលនទ្រព្យត្រូវបានដាក់ឱ្យអនុវត្តចាប់តាំងពីឆ្នាំ២០១១រហូតមក ។

ជារៀងរាល់ឆ្នាំ អគ្គនាយកដ្ឋានពន្ធដារតែងតែជូនដំណឹងអំពីការរំលឹកការបង់ពន្ធ និងការពន្យារពេលបង់ពន្ធ ជាបន្តបន្ទាប់ ក្នុងគោលបំណងសម្រួលដល់ម្ចាស់អចលនទ្រព្យភាគច្រើន ដើម្បីមានពេលវេលាគ្រប់គ្រាន់មកប្រកាសបង់ពន្ធ ប៉ុន្តែអគ្គនាយកដ្ឋានពន្ធដារពិនិត្យឃើញថា នៅតែមានម្ចាស់អចលនទ្រព្យមួយចំនួន មិនទាន់បានមកប្រកាសបង់ពន្ធនៅឡើយ ។ ដូច្នេះ អគ្គនាយកដ្ឋានពន្ធដារសូមក្រើនរំលឹកជាថ្មីម្តងទៀត ដល់ម្ចាស់អចលនទ្រព្យដែលមានអចលនទ្រព្យត្រូវជាប់ពន្ធ មេត្តារួសរាន់មកបំពេញកាតព្វកិច្ចប្រកាសបង់ពន្ធនៅតាមសាខាពន្ធដារខេត្ត-ខណ្ឌដែលអចលនទ្រព្យនោះស្ថិតនៅ ។

ទន្ទឹមនឹងនេះ ដើម្បីឱ្យការប្រមូលពន្ធលើអចលនទ្រព្យប្រព្រឹត្តទៅដោយរលូន អស់លទ្ធភាពនិងសក្តានុពលភាព និងប្រកបដោយតម្លាភាព អគ្គនាយកដ្ឋានពន្ធដារនឹងធ្វើការចុះត្រួតពិនិត្យការអនុវត្តការប្រមូលពន្ធនេះ ក្នុងពេលឆាប់ៗខាងមុខ ។ ក្នុងករណីដែលអចលនទ្រព្យត្រូវជាប់ពន្ធ ហើយពុំទាន់បានបង់ពន្ធលើអចលនទ្រព្យក្នុងអំឡុងពេលនៃការចុះត្រួតពិនិត្យ ម្ចាស់អចលនទ្រព្យត្រូវទទួលរងទោសទណ្ឌបន្ថែមទៀត តាមច្បាប់ជាធរមាន ។ ស្របពេលជាមួយគ្នានោះ រាល់ការលក់ ឬផ្ទេរកម្មសិទ្ធិលើអចលនទ្រព្យ អគ្គនាយកដ្ឋានពន្ធដារនឹងធ្វើការឃាត់ទុក ដោយមិនអនុញ្ញាតឱ្យមានការផ្ទេរកម្មសិទ្ធិឡើយ បើគ្មានការបញ្ជាក់ពីការបង់ពន្ធលើអចលនទ្រព្យទេនោះ ។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមយ៉ាងមុតមាំថា ឯកឧត្តម-លោកជំទាវ លោកឧកញ៉ា អ្នកឧកញ៉ា អស់លោក-លោកស្រី ជាម្ចាស់អចលនទ្រព្យទាំងអស់ដែលស្ថិតនៅក្នុងខណ្ឌនៃរាជធានីភ្នំពេញ និងក្រុងនីមួយៗនៃខេត្តទាំងអស់ ពិតជាយកចិត្តទុកដាក់អញ្ជើញមកបំពេញកាតព្វកិច្ចសារពើពន្ធឱ្យបានទាន់ពេលវេលា មុនការចុះត្រួតពិនិត្យដោយមន្ត្រីនៃអគ្គនាយកដ្ឋានពន្ធដារ ។

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

អគ្គនាយកដ្ឋានពន្ធដារ

**គង់ វិបុល**

**<u>ចម្លងជូន</u>** ÷
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីកសហវ
- សាលារាជធានី-ខេត្ត
  "ដើម្បីជូនជ្រាប"
- សាខាពន្ធដារខេត្ត-ខណ្ឌ
  "ដើម្បីមុខការ"

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី(១១០)និង ម៉ៅសេទុង(២៥៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh